IHSS
IN-HOME SUPPORTIVE SERVICES

CDSS

# ការត្រួតពិនិត្យអ្នកផ្តល់សេវារបស់អ្នក

ក្នុងនាមជានិយោជក អ្នកនឹងត្រូវត្រួតពិនិត្យអ្នកផ្តល់សេវារបស់អ្នក។ នេះអាចធ្វើឱ្យអ្នកមានអារម្មណ៍មិនស្រួល ប្រសិនបើអ្នកមិនធ្លាប់ធ្វើបែបនេះពីមុនមក។ ទោះយ៉ាងណាក៏ដោយ ព័ត៌មានខាងក្រោមអាចជួយអ្នកបាន។

1. **ប្រាប់ឱ្យអ្នកផ្តល់សេវារបស់អ្នកដឹងពីកិច្ចការអ្វីខ្លះដែលត្រូវបំពេញរាល់ពេលដែលគាត់ធ្វើការ។**

   ប្រសិនបើវាហាក់ដូចជាមិនមានពេលវេលាគ្រប់គ្រាន់ដើម្បីធ្វើកិច្ចការដែលមានការអនុញ្ញាតទាំងអស់នោះ អ្នក និងអ្នកផ្តល់សេវារបស់អ្នកគួរនិយាយអំពីរបៀបប្រើប្រាស់ពេលវេលារបស់កម្មវិធី IHSS ដែលត្រូវបានអនុញ្ញាតឱ្យល្អបំផុត។ ប្រសិនបើស្ថានភាពរបស់អ្នកផ្លាស់ប្តូរ ហើយអ្នកត្រូវការម៉ោងច្រើន ឬតិចជាង សូមទាក់ទងការិយាល័យ IHSS ខោនធីរបស់អ្នក។

2. **ទំនាក់ទំនងដោយប្រាប់ឱ្យដឹងពីតម្រូវការរបស់អ្នក។**

   អ្នកផ្តល់សេវារបស់អ្នកត្រូវដឹងពីរបៀបដែលអ្នកចូលចិត្តអ្វីៗដែលបានធ្វើ ដូច្នេះគាត់អាចបំពេញកិច្ចការតាមរបៀបដែលដំណើរការសម្រាប់អ្នក។

   - ត្រូវនិយាយឱ្យច្បាស់លាស់។ ពន្យល់ឱ្យបានលម្អិតតាមដែលអាចធ្វើទៅបានអំពីរបៀបដែលអ្នកចង់ឱ្យអ្នកផ្តល់សេវារបស់អ្នកបំពេញកិច្ចការដែលមានការអនុញ្ញាតនីមួយៗ ។ ត្រូវចងចាំនូវរយៈពេលដែលអ្នកផ្តល់សេវារបស់អ្នកត្រូវបានអនុញ្ញាតសម្រាប់សេវាកម្ម។ អ្នកប្រហែលជាមានភាពស្រួលចិត្តច្រើនជាង ដោយចាប់ផ្តើមពីកិច្ចការដូចជា កិច្ចការផ្ទះ ឬការបោកគក់ មុនពេលនិយាយអំពីតម្រូវការថែទាំផ្ទាល់ខ្លួនណាមួយ។
   - ត្រូវអត់ធ្មត់។ អ្នកប្រហែលជាត្រូវរំលឹកអ្នកផ្តល់សេវារបស់អ្នកអំពីរបៀបដែលអ្នកចង់ឱ្យគាត់ធ្វើកិច្ចការនានា ច្រើនជាងម្តង។
   - ត្រូវនិយាយពីចំណុចជាក់លាក់។ ប្រសិនបើអ្នកចង់ឱ្យកិច្ចការដែលមានការអនុញ្ញាតរបស់អ្នកធ្វើតាមវិធីជាក់លាក់មួយ សូមប្រាប់ឱ្យអ្នកផ្តល់សេវារបស់អ្នកដឹង។

3. **ត្រូវមានភាពសមហេតុផលក្នុងអ្វីដែលអ្នករំពឹងទុក។**

   អ្នកផ្តល់សេវាថ្មីប្រហែលជាត្រូវធ្វើការឱ្យអ្នកពីរបីដង មុនពេលស្វែងយល់ពីការរំពឹងទុក និងតម្រូវការរបស់អ្នក។

4. **ប្រាប់ឱ្យអ្នកផ្តល់សេវារបស់អ្នកដឹងពីរបៀបដែលកិច្ចការនានាៗ កំពុងតែដំណើរការ។**

   - និយាយអ្វីដែលវិជ្ជមាននៅពេលគាត់ធ្វើកិច្ចការនានា តាមរបៀបដែលអ្នកចូលចិត្តឱ្យគាត់ធ្វើ។
   - និយាយអ្វីមួយដើម្បីកែតម្រូវអ្នកផ្តល់សេវារបស់អ្នក នៅពេលដែលកិច្ចការមិនត្រូវបានបញ្ចប់តាមរបៀបដែលអ្នកចង់បាន។ ដោយពាក្យគួរសម ប្រាប់ឱ្យគាត់ដឹងពីរបៀបដែលអ្នកចង់ឱ្យកិច្ចការនានា ត្រូវបានធ្វើ។ គន្លឹះមានប្រយោជន៍មួយចំនួនរួមមានៈ
     - ប្រើសំនៀងមិត្តភាព។
     - កុំបន្ទោស ឬបង្អាប់អ្នកផ្តល់សេវារបស់អ្នក។
     - ប្រព្រឹត្តចំពោះអ្នកផ្តល់សេវារបស់អ្នកដោយការគោរព។

**5. វាជារឿងសំខាន់ដែលអ្នកមិនត្រូវសួរអ្នកផ្ដល់សេវារបស់អ្នក ឱ្យធ្វើកិច្ចការដែលគ្មានការអនុញ្ញាត ឬសេវាកម្មដែលមិនមានការរ៉ាប់រង។**

នៅពេលដែលបុគ្គលិកសង្គមវាយតម្លៃតម្រូវការរបស់អ្នក គាត់នឹងសម្រេចចិត្តថាតើសេវាកម្ម IHSS ណាដែលត្រូវបានអនុញ្ញាតឱ្យអ្នក។ អ្នកមិនគួរស្នើសុំអ្នកផ្ដល់សេវារបស់អ្នកឱ្យធ្វើកិច្ចការដែលមិនត្រូវបានអនុញ្ញាត ឬមិនបានរ៉ាប់រងដោយកម្មវិធី IHSS នោះទេ។ ប្រសិនបើអ្នកត្រូវការជំនួយក្នុងកិច្ចការដែលមិនត្រូវបានរ៉ាប់រងដោយកម្មវិធី IHSS ដូចជាការថែទាំសត្វចិញ្ចឹម ជំនួយជាមួយសំបុត្រ ឬហិរញ្ញវត្ថុ ឬការតាមជូនទៅក្នុងសកម្មភាពសង្គម អ្នកគួរតែសុំសមាជិកគ្រួសារ មិត្តភ័ក្តិ អ្នកស្ម័គ្រចិត្តក្នុងព្រះវិហារ ឬអ្នកផ្សេងទៀតឱ្យជួយអ្នក។ប្រសិនបើអ្នកសម្រេចចិត្តជួលអ្នកផ្ដល់សេវា IHSS របស់អ្នកឱ្យធ្វើការឱ្យអ្នកដើម្បីផ្ដល់ជំនួយជាមួយនឹងកិច្ចការដែលមិនមែនជាសេវាការមើលថែទាំក្នុងផ្ទះ (IHSS) វាគឺជាទទួលខុសត្រូវរបស់អ្នក និងអ្នកផ្ដល់សេវារបស់អ្នកក្នុងការចូលទៅក្នុងការព្រមព្រៀងគ្នាលើការងារ និង/ឬ ការរៀបចំការបង់ប្រាក់សំរាប់ជំនួយជាមួយសេវាកម្មវិធី IHSS មិនបង់ប្រាក់ឱ្យ។

**6. ប្រើប្រាស់ពេលវេលាឱ្យបានល្អ។**

ក្នុងនាមជានិយោជក និងអ្នកត្រួតពិនិត្យរបស់អ្នកផ្ដល់សេវារបស់អ្នក វាគឺជាការងាររបស់អ្នកក្នុងការធ្វើឱ្យប្រាកដថាគាត់កំពុងបំពេញសេវាកម្ម IHSS ក្នុងអំឡុងពេលដែលបានអនុញ្ញាត។ អ្នកផ្ដល់សេវារបស់អ្នកមិនគួរធ្វើអ្វីណាមួយឡើយ លើកលែងតែការផ្ដល់សេវា IHSS ដល់អ្នក ខណៈពេលដែលពួកគេកំពុងត្រូវបានបង់ប្រាក់ឱ្យ ក្នុងនាមជាអ្នកផ្ដល់សេវាការថែទាំសំរាប់កម្មវិធី IHSS ។

អ្នកផ្ដល់សេវារបស់អ្នកមិនគួរះ

- ធ្វើការហៅទូរស័ព្ទផ្ទាល់ខ្លួន
- មើលទូរទស្សន៍
- ចំណាយពេលវេលាជជែកលេងជាមួយអ្នកច្រើនពេក
- នាំកូនក្មេង ឬអ្នកផ្សេងទៀតទៅធ្វើការជាមួយ
- ធ្វើអាជីវកម្ម ឬសកម្មភាពផ្ទាល់ខ្លួនរបស់គាត់

**សំរាប់ព័ត៌មានបន្ថែម សូមទាក់ទងការិយាល័យខោនធីផ្នែក IHSS ក្នុងតំបន់របស់អ្នក។**